**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ០០៩ សហវ.

*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៥*

# សារាចរណែនាំ
## ស្តីពី
## ការគ្រប់គ្រងទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម

៚ * ៚

កន្លងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសង្កេតឃើញបាតុភាពអសកម្មមួយចំនួន ពាក់ព័ន្ធនឹងការនាំចូលទំនិញគ្មានលក្ខណៈពាណិជ្ជកម្មដូចជាទំនិញមានលក្ខណៈពាណិជ្ជកម្មមួយចំនួនធំ ត្រូវបាននាំចូលក្នុងរូបភាពជាទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម ហើយតម្លៃគិតពន្ធគយត្រូវបានកំណត់ដោយបំបែកវិក័យប័ត្រ ដើម្បីតម្រូវតាមសមត្ថកិច្ចរបស់ខ្លួន ឬតេច PSI ។ ករណីជាច្រើន ការនាំចូលពុំបានធ្វើឡើងដោយក្រុមហ៊ុនមានលេខអត្តសញ្ញាណកម្ម អាករលើតំលៃបន្ថែម (VAT IN) ត្រឹមត្រូវឡើយ ទោះបីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាទីចាត់ការគយនិងរដ្ឋាករ បានចេញនូវបទបញ្ញត្តិ និងការណែនាំនានាជាបន្តបន្ទាប់ក្តី ។ ដើម្បីកាត់បន្ថយនូវបាតុភាពអសកម្មនេះ និងដើម្បីឱ្យការអនុវត្តន៍យន្តការផ្តល់ប្រព្រឹត្តិកម្មស្មើភាពដល់ច្រកតំបន់ឱ្យដូចច្រកអន្តរជាតិបានរលូននោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការរំលឹក និងណែនាំបន្ថែមដល់គ្រប់អង្គភាពគយនិងរដ្ឋាករដូចខាងក្រោម៖

១- ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមខ្លឹមសារនៃច្បាប់ និងបទបញ្ញត្តិជាធរមាននានា ជាពិសេសសារាចរលេខ ០០១ ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០០០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបញ្ជាក់បន្ថែម និងការសំរួលនីតិវិធីនៃការកំណត់តម្លៃគិតពន្ធគយ និងតារាងតម្លៃគិតពន្ធគយជាធរមាននានាជាដើម ។

២- ទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម គឺជាទំនិញដែលត្រូវបាននាំចូលម្តងម្កាលដោយអ្នកដំណើរ ឬត្រូវបាននាំចូលដោយប្រជាពលរដ្ឋដែលមានលំនៅដ្ឋានជាអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែន សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬការប្រើប្រាស់ក្នុងតំបន់ព្រំដែន ។

៣- ការនាំចូលម្តងម្កាលរបស់អ្នកដំណើរ ដែលត្រូវចាត់ទុកថាគ្មានលក្ខណៈពាណិជ្ជកម្ម ត្រូវបំពេញបែបបទគយតាមច្បាប់ជាធរមាន ដោយត្រូវបង្ហាញនូវលិខិតឆ្លងដែន ដែលមានការបញ្ជាក់ពីការចេញ- ចូលប្រទេសពីស្ថាប័នមានសមត្ថកិច្ចច្រកទ្វារ ហើយត្រូវប្រថាប់ត្រា ឬសរសេរលើបង្កាន់ដៃពន្ធថា "គ្មានលក្ខណៈពាណិជ្ជកម្ម- សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន" និងពុំបាច់បិទត្រាគយឡើយ។ ក្នុងករណី

ដែលអ្នកដំណើរម្តងម្កាលនោះនាំចូលទំនិញហើយ ប្រកាសថាមានលក្ខណៈពាណិជ្ជកម្មសំរាប់ធ្វើអាជីវកម្ម ការកំណត់តម្លៃគិតពន្ធគយត្រូវបូកបន្ថែម ២០ភាគរយ លើតម្លៃគិតពន្ធគយជាធរមាន និងត្រូវប្រថាប់ត្រា ឬសរសេរលើបង្កាន់ដៃពន្ធថា "មានលក្ខណៈពាណិជ្ជកម្ម" ហើយត្រូវបិទត្រាគយជូនប្រសិនបើមុខទំនិញនោះស្ថិតក្រោមប្រព័ន្ធត្រាគយ ដើម្បីអាចចរាចរលើទីផ្សារបាន ។

៤- ចំពោះការនាំចូលរបស់ប្រជាជនដែលមានលំនៅដ្ឋានជាអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែន ត្រូវបំពេញបែបបទគយតាមការកំណត់ជាធរមាន ហើយត្រូវប្រថាប់ត្រា ឬសរសេរលើបង្កាន់ដៃពន្ធថា "សំរាប់ចរាចរក្នុងតំបន់ព្រំដែន" ។ ប្រជាជនតំបន់ព្រំដែន ដែលធ្វើអាជីវកម្មនាំចេញ- នាំចូលទំនិញមានលក្ខណៈពាណិជ្ជកម្មសំរាប់ចរាចរទៅទូទាំងប្រទេសនោះ ត្រូវតែបង្កើតជាក្រុមហ៊ុនដែលមានលេខអត្តសញ្ញាណកម្ម អាករលើតំលៃបន្ថែម និងត្រូវមានប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយដូចអ្នកនាំចេញ- នាំចូលធម្មតា ហើយក្នុងករណីចាំបាច់ ត្រូវអនុវត្តដូចការណែនាំក្នុងចំណុចទី ៣ ខាងលើនេះ ។

៥- ការនាំចេញ- នាំចូលផ្សេងទៀត ក្រៅពីមានចែងក្នុងចំណុច ៣ និង ៤ ខាងលើ ត្រូវតែធ្វើឡើងដោយបុគ្គលដែលមានលេខអត្តសញ្ញាណកម្ម អាករលើតម្លៃបន្ថែម និងមានប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ ។ ករណីផ្សេងពីនេះ ត្រូវមានការអនុញ្ញាតដោយឡែកពីទីចាត់ការគយនិងរដ្ឋាករ ។

៦- ការប្រើប្រាស់ច្បាប់ចំលងនៃវិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម និងប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ ត្រូវមានការបញ្ជាក់ជាលាយលក្ខអក្សរលើនោះពីបណ្ណាធិការក្រុមហ៊ុន អមដោយលិខិតផ្ទេរសិទ្ធិច្បាប់ដើម អត្តសញ្ញាណប័ណ្ណរបស់អ្នកទទួលសិទ្ធិ ឬបំពេញបែបបទគយ ដែលចុះហត្ថលេខាដោយបណ្ណាធិការ និងមានប្រថាប់ត្រាសាមីក្រុមហ៊ុនលើនោះ ហើយក្នុងករណីចាំបាច់ត្រូវទំនាក់ទំនងផ្ទៀងផ្ទាត់ជាមួយក្រុមហ៊ុននោះឡើងវិញ ។

ទីចាត់ការគយនិងរដ្ឋាករ ត្រូវចាត់ចែងផ្សព្វផ្សាយ និងណែនាំដល់គ្រប់អង្គភាពគយនិងរដ្ឋាករដែលមានការពាក់ព័ន្ធ ឱ្យទទួលអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ តទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានគណៈកម្មការអន្តរក្រសួងទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធ

គាត ឈន់

ចម្លងជូន :

- គ្រប់សភាពាណិជ្ជកម្ម ខេត្ត- ក្រុង
  "ដើម្បីជ្រាប និងចូលរួមផ្សព្វផ្សាយ អនុវត្ត"
- ឯកសារ- កាលប្បវត្តិ